**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីអំពាវនាវ

អនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីសម្ព័ន្ធមេត្រីភាពរវាងកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន អង្គភាពស៊ីវិល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងក៏ដូចជាភ្នាក់ងារជ្រើសរើសឯកជន និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនទាំងអស់ មេត្តាជ្រាបថា ដើម្បីរឹតចំណងសម្ព័ន្ធមេត្រីភាពជាមួយកងពលតូចអន្តរាគមន៍លេខ ៧ ដែលកំពុងឈរជើងការពារនៅតាមតំបន់ព្រំដែនខេត្តព្រះវិហារ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនេះ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** នឹងដឹកនាំគណៈប្រតិភូចុះសួរសុខទុក្ខបងប្អូន និងគ្រួសារយុទ្ធជន នៅថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ០៨:៣០នាទីព្រឹក នៅទីបញ្ជាការកងពល ស្ថិតក្នុងភូមិសែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

ក្នុងស្មារតីនេះ ក្រសួងសូមអំពាវនាវដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ មេត្តាជួយឧបត្ថម្ភថវិកា សម្ភារ និងគ្រឿងឧបភោគបរិភោគនានាតាមសទ្ធាជ្រះថ្លា ដើម្បីលើកទឹកចិត្ត និងគាំទ្រដល់ស្មារតីស្នេហាជាតិរបស់បងប្អូនកងទ័ពយើង។

ក្រសួងសង្ឃឹមជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងចូលរួមគាំទ្រសកម្មភាពនេះ ដើម្បីរួមចំណែកជាមួយកងពលខាងលើឱ្យបានច្រើនកុះករ។

<u>បញ្ជាក់</u> ៖ រសៀលថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២ ចេញដំណើរដោយមធ្យោបាយផ្ទាល់ខ្លួន។

ថ្ងៃចន្ទ ១២កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២២

<u>សូមទំនាក់ទំនងឧទ្ទេកាល័យ៖</u>

-លោក អ៊ុច ពិសី ០១៦ ៩០២ ៩០៤

-លោកស្រី ជា សុខេន ០៧៧ ៧០០ ៧២៦